**កម្មវិធីសាធារណៈ**
*គម្រោងបណ្ណសារសិល្បៈសឹង្ហបុរីនៅស-សបាសាក់៖ កូ ហួង ហាវ និង ស៊ូ ទិត្យ ស៊ីង*
រៀបចំពិព័រណ៌ដោយ វ៉េរ៉ា ម៉ៃ និង ម៉េឡានី មឺម៉ត
សសបាសាក់ ភ្នំពេញ កម្ពុជា
ថ្ងៃទី ៣១ ខែកក្កដា ដល់ថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៦

*សិក្ខាសាលា (ជាភាសាខ្មែរ)*
ថ្ងៃទី៦ និង៧ ខែសីហា ឆ្នាំ ២០១៦
រួមសហការជាមួយនឹង Betonsalon នៅប៉ារីស និងគម្រោងសិល្បៈសស នៅភ្នំពេញ *រោងកុននៃចលនា* គឺជាសិក្ខាសាលាល្អិតល្អន់មួយ សម្របសម្រួលដោយសិល្បករ និងអ្នកដឹកនាំគម្រោងសិល្បៈស-ស លោក វុទ្ធ លីណូ។ កម្មវិធីនេះនឹងប្រមូលផ្តុំនូវសិល្បករ និងអ្នកចូលរួមក្មេងៗ ដែលមានទីលំនៅជិតអាគារសរបស់ក្រុងភ្នំពេញ ដើម្បីជម្រុញឲ្យមានការអង្កេតជារួមមួយស្តីពីចលនាឆ្លងវប្បធម៌ ដែលភាគច្រើនទាក់ទងនឹងឯកសារនៅបារាំង។ សំណើរ និងស្នាដៃដែលត្រូវបានបង្កើតឡើងនៅក្នុងសិក្ខាសាលានេះនឹងត្រូវបានបង្ហាញម្តងទៀតនៅការតាំងពិព័រណ៍ *នៅគ្រប់កន្លែងលើកលែងតែទីនេះ* (ថ្ងៃទី ១៣ ខែកញ្ញា ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០១៦) របស់ Bétonsalon ដែលត្រូវបានរៀបចំរួមគ្នាដោយ អ្នកនាង ម៉ី និង អ្នកនាងមឺម៉ត។ វានឹងពាំនាំមកនូវស្នាដៃដែលរុករកចលនាដ៏ស្រទន់របស់វត្ថុ មនុស្ស ឬកាយវិការ ដែលទាក់ទងនឹងប្រទេសកម្ពុជា និងបរិបទភូមិសាស្ត្រនៃអាស៊ីអាគ្នេយ៍ជារួមផងដែរ។

*ការបង្រៀន និងការដើរបង្ហាញ (ជាភាសាអង់គ្លេស ជាមួយនឹងការបកប្រែជាភាសាខ្មែរ)*
ថ្ងៃព្រហស្បត្តិ៍ ទី ១១ ខែសីហា
៦៖៣០ ដល់ ៧៖៣០ នៅសសបាសាក់
«អប្សរាជានិមិត្តរូបតំណាងតំបន់៖ ស៊ូ ទិត្យ ស៊ីង និងក្រុមសិល្បៈបុរសដប់នាក់នៅកម្ពុជា» ដោយ វ៉េរ៉ា ម៉ៃ។
ដោយធ្វើការសហការគ្នាជាមួយនឹង «វេទិការប្រវត្តិសិល្បៈ៖ Art History Forum» ការបង្រៀននេះផ្តោតសំខាន់ ទៅលើរូបអប្សរាដែលចេញមកម្តងហើយម្តងទៀត នៅក្នុងការងាររបស់ស៊ូ ទិត្យ ស៊ីង។ សម្រាប់លោកស៊ូ និងក្រុមសិល្បៈបុរសដប់នាក់ *អប្សរា* គឺជានិមិត្តរូបនៃតំបន់ទាំងមូល ដែលអាចផ្សារភ្ជាប់សោភ័ណភាពរបស់តំបន់ អាស៊ីអាគ្នេយ៍ទៅនឹងបទពិសោធន៍នានា។

*ការដើរបង្ហាញជាមួយនឹងសិល្បករ * (ជាភាសាខ្មែរ អង់គ្លេស និង បារាំង)*
ថ្ងៃសៅរ៍ ទី១៦ ខែសីហា
២៖៣០ ដល់ ៣៖៣០ រសៀល (ភាសាអង់គ្លេស ជាមួយនឹងការបកប្រែជាភាសាខ្មែរ)
៤៖៣០ ដល់ ៥៖៣០ ល្ងាច (ភាសាបារាំង)
ចូលរួមការដើរបង្ហាញដ៏ស្និតរមួតមួយជាមួយនឹងស្នាដៃខ្លះៗរបស់បណ្ណសារ និងការតាំងពិពណ៌របស់សិល្បករ កូ ហួង ហាវ។
*ពួកយើងសូមគោរពអញ្ជើញសាលា និងទស្សនិកជនដែលមានបំណងចូលរួមមកទាក់ទងយើងខ្ញុំដើម្បីធ្វើការ ដើរបង្ហាញឯកជននៅអំឡុងពេលដែលគម្រោងនៅបន្តធ្វើ។

*កម្មវិធីចាក់ខ្សែភាពយន្ត*
ថ្ងៃព្រហស្បត្តិ៍ ទី ២៥ ខែសីហា ម៉ោង ៦៖៣០ ល្ងាច នៅ បុប្ផាណា ផ្ទះលេខ ៦៤ ផ្លូវ ២០០ ឧកញ៉ាម៉ែន ភ្នំពេញ
ក្រុមសិល្បៈបុរសដប់នាក់បានមកលេងប្រទេសកម្ពុជានៅឆ្នាំ១៩៦៣ គឺបួនឆ្នាំមុនកើតអាស៊ានដើម្បីជម្រុញឲ្យ មានស្ថិរភាពក្នុងតំបន់ និងការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ហើយជាពេលដែលគេគិតថាជា «យុគសម័យមាស» របស់ប្រទេសកម្ពុជា។ ពេលនោះ តំបន់នេះកំពុងជួបប្រទះចលនាផ្លាស់ប្តូរធំៗជាច្រើន ដែលក្នុងនោះប្រទេស កម្ពុជានៅតែបន្តជជែកពិភាក្សាអំពីស្ថានភាពមិនចូលបក្សសម្ព័ន្ធក្នុងបញ្ហាដែលកើតឡើងថ្នាក់ជាតិ និងថ្នាក់ តំបន់ដោយសារសង្គ្រាមត្រជាក់។ រីឯសហព័ន្ធម៉ាឡាយ៉ា បនេអូខាងជើង សារ៉ាវ៉ាក់ និងសឹង្ហបុរីបានចូលគ្នាដើម្បីបង្កើតប្រទេសម៉ាឡេស៊ីនៅឆ្នាំ១៩៦៣ ជាមួយនឹងការបញ្ចេញប្រទេសសឹង្ហបុរីចេញ និងទទួលបានឯករាជ្យជាតិនាឆ្នាំ១៩៦៥។ ដោយប្រើប្រាស់ទិន្នន័យឯកសារដែលមានវីដេអូជាង ៧០០ ម៉ោងទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជារបស់ មជ្ឈមណ្ឌលធនធានសោតទស្សន៍ និងរូបភាព បុប្ផាណា អ្នករៀបរៀងកម្មវិធី អ្នកនាង ម៉ាកហ្គ បូណូផ៉េរ៉ា នឹងផ្តុំគ្នានូវខ្សែភាពយន្តមួយចំនួន ៩០ នាទីដើម្បីធ្វើការបង្ហាញពីភាពស្មុគស្មាញនៃផ្នែកសង្គមនយោបាយ របស់ *គម្រោងឯកសារសិល្បៈសឹង្ហបុរី*។

## ជីវៈប្រវត្តិ

**កូ ហ្វួង ហាវ** បានចាប់ផ្តើមធ្វើការងារសិល្បៈនៅឆ្នាំ ១៩៨៨។ ស្នាដៃ របស់គាត់រួមមានការថតរូប ការប្រើក្រដាស បង្កើតរូបភាព ការប្រមូលផ្តុំ ការដំឡើងសិល្បៈសម្តែង ការកត់ត្រា ការប្រមូលឯកសារ ការរៀបចំពិព័រណ៍ និងការស្រាវជ្រាវ។ គាត់បានបម្រើការនៅ សាលពិព័រណ៍សិល្បៈ សារៈមន្ទីរជាតិ ជាជំនួយការសារៈមន្ទីរ ពីខែតុលា ឆ្នាំ ១៩៨៥ ដល់ខែធ្នូ ឆ្នាំ ១៩៩១។ គាត់បានលាឈប់ពីមុខតំណែងនេះដើម្បីធ្វើការងារទាក់ទងនឹងបណ្ណសារ និង ស្នាដៃរបស់សិល្បៈករផ្សេងៗ និងឯកសារផ្សេងៗដែលសារៈមន្ទីរ មិនបានប្រមូលទុក។ គាត់បានចូលរួមភូមិសិល្បករ និងធ្វើការកត់ត្រាសកម្មភាពរបស់ពួកគេដោយប្រើប្រាស់រូបថត ( ១៩៨៩ ដល់ ១៩៩៩ )។ គាត់ជាអ្នកស្រាវជ្រាវ នៅឯកម្មវិធីអ្នកស្រាវជ្រាវ ឬអ្នករៀបចំពិពណ៍ស្នាក់នៅឆ្នាំ១៩៩៩ របស់សារៈមន្ទីរសិល្បៈអាស៊ីហ្វូកុកា និងបានផ្តួចផ្តើម គម្រោងបណ្ណសារសិល្បៈសឹង្ហបូរី ( ២០០៥ ដល់បច្ចុប្បន្ន ) ដែលធ្វើការកត់ត្រា និងរក្សាទុកយ៉ាងសកម្មនូវធនធានដែលទាក់ទងនឹងសិល្បៈរបស់ប្រទេសសឹង្ហបូរី។

**ស៊ូ ទិត្យ ស៊ីង** ( ១៩១៤ ដល់១៩៩៧ ) ជាអ្នកអប់រំ អ្នកយកពត៌មាន និងសិល្បករ ដែលចាប់ផ្តើមរៀនសិល្បៈ នៅឆ្នាំ១៩៣៥ នៅមហាវិទ្យាល័យវិចិត្រសិល្បៈជាតិហាងចូវ ផ្តោតសំខាន់ទៅលើគំនូរលោកខាងលិច និងគំនូរទឹកខ្មៅចិន។ គាត់ជាជាងថតរូប ជាងគំនូរប្រើជក់ និងជាងឆ្លាក់រូបជីសកម្មមួយរូប រួមដោយការតាំងពិពិរណ៍យ៉ាង ច្រើនពីឆ្នាំ ១៩៤៦ ដល់អំឡុងឆ្នាំ ១៩៩០ ជាង។ គាត់ក៏ធ្លាប់បានធ្វើការតាំងពិព័រណ៍នៅសាលពិព័រណ៍សិល្បៈសារៈមន្ទីរជាតិរបស់សឹង្ហបូរីផងដែរ។ លោកស៊ុយ បានធ្វើដំណើរនៅតំបន់អាស៊ីអាគ្នេយ៍ពីអំឡុងទសវត្សទី ៦០ និង ៧០។ គាត់ក៏ជាសមាជិករបស់ក្រុមសិល្បៈបុរសដប់នាក់ និងសហគមន៍សិល្បៈអាស៊ីអាគ្នេយ៍ផងដែរ។

**វ៉ោ ម៉ៃ** គឺជាអ្នករៀបចំពិព័រណ៍ឯករាជ្យមួយរូប ហើយបានទទួលអាហាររូបករណ៍ដើម្បីបន្តការសិក្សាថ្នាក់បណ្ឌិតនៅ SOAS សាកលវិទ្យាល័យឡុងដ៍ ដែលនឹងចាប់ផ្តើមនៅខែកញ្ញា ឆ្នាំ ២០១៦។ មុននេះ គាត់បានធ្វើជាអ្នករៀបចំពិព័រណ៍ ស្នាក់នៅនិវាសនដ្ឋាន ដែលជាផ្នែកមួយនៃក្រុមបង្កើតរបស់មជ្ឈមណ្ឌល NTU សម្រាប់សិល្បៈសហសម័យ សឹង្ហបូរី ដឹកនាំដោយ Ute Meta Bauer។ នៅឆ្នាំ ២០១៥ – ២០១៦ គាត់ជានិស្សិតរបស់មូលនិធិ Getty Foundation ជាផ្នែកមួយនៃ *ការសម្របមហិច្ឆិតា៖ ប្រវត្តិសាស្រ្តថ្មីស្តីពីសិល្បៈអាស៊ីអាគ្នេយ៍* និងជាសមាជិកនៃ គណៈកម្មាធិការកែសម្រួល និងបង្កើតនៃ *ភាគអាគ្នេយ៍នៃសម័យបច្ចុប្បន្ន៖ ទិសដៅរបស់សិល្បៈសហសម័យ និងទំនើប*។ គាត់ក៏បានសហការរៀបរៀងការតាំងពិព័រណ៍ *គម្រោង SEA* ( ជាឈ្មោះបច្ចុប្បន្ន ) ដែលនឹងបើកសម្ពោធនៅសារៈមន្ទីរសិល្បៈម៉ូរី និង មជ្ឈមណ្ឌលសិល្បៈជាតិតូក្យូនៅខែកក្កដា ឆ្នាំ ២០១៧។

**ម៉េឡានី ប៊ីម៉ត** គឺជាអ្នករៀបចំពិព័រណ៍ឯករាជ្យ និងអ្នកស្រាវជ្រាវឯករាជ្យ ដែលមានទីលំនៅនៅទីក្រុងប៉ារីស។ គាត់បានបញ្ចប់ការសិក្សាផ្នែកប្រវត្តិសាស្រ្តសិល្បៈ នៅឯមហាវិទ្យាល័យឡាវសេន របស់ប្រទេស Switzerland។ ទន្ទឹមនឹងនេះផងដែរ គាត់ក៏ធ្វើការជាអ្នកគ្រប់គ្រងផ្នែកស្រាវជ្រាវលើការតាំងពិព័រណ៍នៅមជ្ឈមណ្ឌល Pompidou មជ្ឈមណ្ឌល Pompidou–Metz ឬ Generali Fondation។ គាត់ក៏បានបង្កើតគម្រោងរៀបរៀងពិព័រណ៍ដូចជា សិក្ខាសាលាពិសោធន៍ */ Jikken kōbō* ( Bétonsalon, ប៉ារីស, ២០១១ ), *EFVJ* ( AP News, ហ្ស៊ូរិច, ២០១២ ), ការស្រាវជ្រាវ *APN あぷん* ( Kunsthalle Bern, ២០១២ ), ៤១° *លើសពីមូលហេតុ* ( Ensba, Résonance Biennale de Lyon, ២០១៣ ) and *Louvain Biennal* ( Belgium, ២០១៤ ) ។ គាត់បានចូលរួមកម្មវិធីអ្នករៀបរៀងពិព័រណ៍វ័យក្មេង នៅ Berlin Biennale ( ២០១៤ )។ នាពេលបច្ចុប្បន្ននេះ គាត់គឺជាអ្នកដឹកនាំកម្មវិធីនៅមជ្ឈមណ្ឌល Bétonsalon សម្រាប់សិល្បៈ និងការស្រាវជ្រាវនៅទីក្រុងប៉ារីស។

**ម៉ាកហ្គ បូណូផេរ៉ា** ធ្វើការរវាងទីក្រុងប៉ារីស និងទីក្រុងឡុងដ៍។ គាត់មានសញ្ញាបត្របរិញ្ញាបត្រប្រវត្តិសាស្រ្តសិល្បៈ École du Louvre នៅទីក្រុងប៉ារីស។ បច្ចុប្បន្ននេះ គាត់កំពុងសិក្សាដើម្បីទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែក កម្មវិធីអភិរក្ស នៅមហាវិទ្យាល័យភូមិន្ទសិល្បៈ នៅទីក្រុងឡុងដ៍។ គាត់បានធ្វើការ ជាជំនួយការចម្បងរបស់ Grazia Quaroni មូលនិធិ Cartier Foundation ទីក្រុងប៉ារីស សម្រាប់ការតាំងពិព័រណ៍ និងឯកសាររបស់ Bruce Nauman។ ហើយគាត់ក៏ជាអ្នករៀបចំការតាំងពិពិរណ៍របស់ Andréa Vamos នៅផ្ទះរបស់ Cocteau នៅ Milly-la-Forêt ប្រទេសបារាំង ( ២០១៥ )។ បច្ចុប្បន្ននេះ បូណូផេរ៉ាគឺជាអ្នករៀបរៀងពិព័រណ៍របស់សាលពិព័រណ៍ខូហ្គាន នៅទីក្រុងប៉ារីស។ គាត់គឺជាអ្នកហាត់ការនៅស-សបាសាក់ នៅខែកក្កដា ដល់ខែសីហា ឆ្នាំ២០១៦។

## អំពីដៃគូរបស់យើង

មូលនិធិអាស៊ីញូវហ្សេឡង់
*គម្រោងឯកសារសិល្បៈសឹង្ហបូរីនៅស-សបាសាក់៖ កូ ហ្វួង ហាវ និង ស៊ូ ទិត្យ ស៊ីង* ដែលត្រូវបានឧបត្ថម្ភមួយផ្នែកដោយ មូលនិធិអាស៊ីញូវហ្សេឡង់។
http://www.asianz.org.nz

មជ្ឈមណ្ឌល **Bétonsalon** សម្រាប់សិល្បៈ និងការស្រាវជ្រាវ ខិតខំប្រឹងប្រែងបង្កើតនូវទីកន្លែងមួយសម្រាប់ ការឆ្លុះបញ្ចាំង និងការប្រឈមជាមួយនឹងចំនុចប្រសព្វរវាងសិល្បៈ និងការស្រាវជ្រាវរបស់សាកលវិទ្យាល័យ ដោយផ្តល់ទម្រង់ក្នុងការជជែកពិភាក្សាពីផ្នែកសោភ័ណ វប្បធម៌ នយោបាយ សង្គម និងសេដ្ឋកិច្ច។ Bétonsalon ត្រូវបានគេរួមបញ្ចូលក្នុងសាកលវិទ្យាល័យប៉ារីស ៧ នៅកណ្តាលតំបន់មួយដែលកំពុងនៅក្រោមការសាងសង់ឡើង វិញគឺ ZAC Paris Rive Gauche នៅសង្កាត់ទី១៣ នៃទីក្រុងប៉ារីស។ Bétonsalon មានបំណងរួបរួមទ្រឹស្តី និងការអនុវត្តន៍ ដោយមានគោលបំណងក្នុងការគិតឡើងវិញពីមុខងាររបស់ការស្រាវជ្រាវ និងការបង្កើតផ្នែក សិល្បៈនៅក្នុងសង្គម។ នៅខែកុម្ភៈ ឆ្នាំ២០១៦ Bétonsalon បានបង្កើត Villa Vassilieff នៅខណ្ឌទី១៥ នៃប៉ារីស ដែលជាទីកន្លែងមួយសម្រាប់សិល្បៈ ការស្នាក់នៅ និងការស្រាវជ្រាវ។
www.betonsalon.net និង http://www.villavassilieff.net

**មជ្ឈមណ្ឌលធនធានសោតទស្សន៍ និងរូបភាពបុប្ផាណា** គឺជាមជ្ឈមណ្ឌលធនធានសោតទស្សន៍ និងរូបភាព ដែលបង្កើតឡើងនៅឆ្នាំ២០០៦ ដោយលោក រិទ្ធី ប៉ាន់។ មណ្ឌលមានគោលបំណងច្រើន រួមមានឯកសារដែលគេអាចរកបានដោយសេរី និងមិនគិតថ្លៃ ការបង្រៀនផ្នែកពហុផ្សព្វផ្សាយ ពត៌មាន និងការអប់រំ ការបង្កើតខ្សែភាពយន្ត ទីកន្លែងសម្រាប់ការតាំងពិព័រណ៍ ទីកន្លែងចាក់ភាពយន្ត និងកម្មវិធីសាធារណៈមួយដែលផ្តោតសំខាន់ទៅលើប្រវត្តិសាស្រ្តរបស់ប្រទេសកម្ពុជា។ www.bophana.org

**គម្រោងសិល្បៈស-ស ( SSAP )** គឺជាការផ្តួចផ្តើមមិនស្វែងរកប្រាក់កម្រៃរបស់សិល្បករ ដែលធ្វើឡើងសម្រាប់ ការងារសិល្បៈពិសោធន៍។ វាត្រូវបានបង្កើតឡើងដោយ ក្រុម *ស្ទាវសិល្បៈ* និងមានទីតាំងនៅអាគារសរបស់ទីក្រុងភ្នំពេញ។ SSAP ផ្តោតសំខាន់ទៅលើការស្នាក់នៅ ថ្នាក់រៀន និង សិក្ខាសាលា និងគម្រោងរួម សិល្បៈពិសោធន៍ ដោយពឹងផ្អែកលើទំនាក់ទំនងជាមួយនឹងជនជាតិខ្មែរ និងសិល្បករដែលមកទស្សនកិច្ច បុគ្គល និងក្រុមដែលមានគំនិតច្នៃប្រឌិត សិស្សានុសិស្ស និងអ្នករស់នៅក្នុងអាគារសផងដែរ។ www.sasaart.info

**វេទិការប្រវត្តិសិល្បៈ៖ Art History Forum** គឺជាវេទិការមួយសម្រាប់ការជួបប្រជុំ និងពិភាក្សាពី ប្រវត្តិសាស្រ្តសិល្បៈរបស់កម្ពុជា និងប្រទេសផ្សេងៗ។ វេទិការនេះបង្ហាញព្រឹត្តិការណ៍បន្តបន្ទាប់គ្នាផ្នែកអប់រំ និងសាលារៀន ក្រោមរូបភាពជាការបង្រៀន ការពិភាក្សា សិក្ខាសាលា ឬសន្និសិទផ្សេងៗ។ វេទិការនេះមានគោលបំណងសម្របសម្រួលការពិភាក្សាស្តីពីប្រវត្តិសាស្រ្តសិល្បៈរបស់កម្ពុជា និងប្រទេសផ្សេងៗ ជាមួយនឹងទស្សនិកជនភាគច្រើនជាប្រជាពលរដ្ឋនៅទីក្រុងភ្នំពេញ។
www.facebook.com/arthistoryforum

***AUGUST PUBLIC PROGRAM***

*Singapore Art Archive Project @ SA SA BASSAC: Koh Nguang How and Shui Tit Sing*
Curated by Vera Mey and Mélanie Mermod
SA SA BASSAC, Phnom Penh, Cambodia
July 31 – October 8, 2016

***Workshop (in Khmer)***

August 6-7, 2016
In collaboration with Bétonsalon, Paris, and Sa Sa Art Projects/SAAP, Phnom Penh, *Theater of Movements* is an intensive workshop facilitated by artist and SAAP Director Vuth Lyno. It gathers artists and young participants based in Phnom Penh's White Building neighbourhood to call for a collective enquiry on transcultural movements mainly related to archive and documents based in France. Traces of the workshop will resurface in the Bétonsalon exhibition *Anywhere But Here (*September 13 – October 31, 2016) co-curated by Mey and Mermod, which brings together artworks that seek out subtle movements of objects, figures or gestures in relation to Cambodia, and more broadly within the geopolitical context of Southeast Asia.

***Lecture (in English with Khmer translation)***

Thursday, 11 August, 6:00-7:30PM @ SA SA BASSAC
"The Apsara as the Symbol of the Region: Shui Tit Sing and the Ten Men Art Group in Cambodia" by Vera Mey
In collaboration with "Vetika Brovoat Selapak: Art History Forum", this lecture focuses on the recurring figure of the apsara in Shui Tit Sing's practice. For Shui and the Ten Men Art Group, the *apsara* functioned as a pan-regional symbol, which could link diverse Southeast Asian aesthetics and experiences.

***Walkthrough with the artist****

Saturday, 16 August @ SA SA BASSAC
2.30 – 3.30PM (English with Khmer translation)
4.30 – 5.30PM (French)
Join an intimate walkthrough of select materials in the archive and exhibition with artist Koh Nguang How. * Throughout the duration of the project, we invite schools and interested audiences to contact us for a private walkthrough by appointment.

***Screening Program***

Thursday, August 25, 6:30PM @ Bophana, #64, 200 Oknha Men, Phnom Penh
The Ten Men Art Group visited Cambodia in 1963, four years before the Association of Southeast Asian Nations (ASEAN) was established to promote regional stability and economic development, and during the height of what is widely considered Cambodia's "Golden Age." The region was undergoing pivotal moments of flux – Cambodia constantly renegotiating its non-aligned status amidst national and regional manifestations of Cold War conflict, while the Federation of Malaya, North Borneo, Sarawak and Singapore formed Malaysia in 1963, with Singapore expelled and thus independent by 1965. Drawing on Bophana Audiovisual Resource Centre's exceptional documentary database, which holds over 700 hours of video relating to Cambodia's histories, the program curator Margaux Bonopera collates a 90-minute screening dedicated to highlighting and complicating the socio-political dimensions of the *Singapore Art Archive Project.*

## *BIOGRAPHIES*

**Koh Nguang How**'s artistic practice began in 1988 and encompasses photography, collage, assemblage, installation, performance art, documentation, archiving, curating and research. He worked in the National Museum Art Gallery as a Museum Assistant from October 1985 to December 1991. He forfeited this position to develop an artistic practice through working the archive and working on artists' artworks and documents that the museum couldn't collect. He joined The Artists Village and photo-documented their activities (1989-1999). He was a researcher in the pilot Fukuoka Asian Art Museum Researcher/Curator in Residence Program 1999 and initiated the Singapore Art Archive Project (2005 – ongoing) which actively documents and archives materials relating to the Singapore art scene.

**Shui Tit Sing** (1914 – 1997) was an educator, journalist, and artist who commenced his artistic training in 1935 at the Hangzhou National Fine Art College in Western painting and Chinese ink painting. An avid photographer, painter and sculptor, Shui remained active within exhibitions from 1946 to early 1990s, including at the National Museum Art Gallery in Singapore. Shui spent the 1960s and 1970s travelling through Southeast Asia and was a member of The Ten Men Art Group and the Southeast Asian Art Association.

**Vera Mey** is an independent curator and has been awarded a studentship to undertake a PhD at SOAS, University of London commencing in September 2016. Prior to this she was Curator, Residencies as part of the founding team of the NTU Centre for Contemporary Art Singapore led by Ute Meta Bauer. For 2015-2016 she was a Getty Foundation scholar as part of *Ambitious Alignments: New Histories of Southeast Asian Art* and is on the founding editorial committee of *Southeast of Now: Directions in Contemporary and Modern Art*. She is co curator of *SEA Project* (working title) due to open at the Mori Art Museum and National Art Centre Tokyo in July 2017.

**Mélanie Mermod** is an independent curator and researcher based in Paris. She graduated in art history at the University of Lausanne in Switzerland. In parallel to her activities as Research Manager on exhibitions at the Centre Pompidou, Centre Pompidou–Metz or Generali Fondation, Mermod developed curatorial projects such as *Experimental Workshop / Jikken kōbō* ( Bétonsalon, Paris, 2011), *EFVJ* (AP News, Zurich, 2012), *APN Research あぷん* (Kunsthalle Bern, 2012), *41° Beyond Reason* (Ensba, Résonance Biennale de Lyon, 2013) and *Louvain Biennal* (Belgium, 2014). She participated in the Young Curator Program, Berlin Biennale (2014). She is currently Head of Programs at Betonsalon–Center for Art and Research in Paris.

**Margaux Bonopera** works between Paris and London. She holds a BA, Art History, École du Louvre, Paris, and is currently undertaking the MA Curating program, Royal College of Art, London. She was the main assistant of Grazia Quaroni, Cartier Foundation, Paris for Bruce Nauman exhibition and archive, and in charge of the exhibition of Andréa Vamos, Cocteau's house in Milly-la-Forêt, France (2015). Bonopera is curator for the Kogan Gallery, Paris. She is SA SA BASSAC intern in July-August, 2016.

## *PARTNERS*

**Asia New Zealand Foundation**
*Singapore Art Archive Project @ SA SA BASSAC: Koh Nguang How and Shui Tit Sing* is possible with support in part from Asia New Zealand Foundation.
http://www.asianz.org.nz

**Bétonsalon – Center for Art and Research** strives to develop a space of reflection and confrontation at the confluence of art and university research by giving form to discourses in the aesthetic, cultural, political, social and economic realms. Bétonsalon aims to ally theory and practice, with the objective of rearticulating the position of research and artistic creation in society. In February 2016, Bétonsalon opened Villa Vassilieff in the 15th arrondissement of Paris, a space for art, residencies and research. www.betonsalon.net
http://www.villavassilieff.net/

**Bophana Audiovisual Resource Centre** is an audiovisual resource center in Phnom Penh founded in 2006 by Rithy Panh and is dedicated to restoring, protecting and enhancing of audiovisual heritage related to Cambodia's histories through a freely accessible database of archives, multimedia training and education, film production, exhibition space, screening rooms, a public program and more. www.bophana.org

**Sa Sa Art Projects (SSAP)** is a non-profit artist-run initiative dedicated to experimental art practices. Founded by Stiev Selapak collective in 2010 and based in the historic Phnom Penh's White Building, SSAP focuses on Pisaot experimental art residency, classes and workshops, and collaborative projects, through engagement with Cambodian and visiting artists, creative individuals and groups, students, and the White Building's residents.
www.**sasaart**.info

**Vetika Brovoat Selapak: Art History Forum** is a platform for meeting and talking about Cambodian and other art histories. It presents an ongoing series of educational and scholarly events, in the form of lectures, discussions, workshops, or symposia. The aim is to facilitate the discussion of Cambodian and other art histories with a primarily Cambodian audience in Phnom Penh. www.facebook.com/arthistoryforum